អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះចាប់ផ្តើមសវនាការស្តាប់ទឡ្ហីករណ៍ពីភាគីនៅក្នុងសំណុំរឿង ០០៤/២

ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាប់ផ្តើមសវនាការរយៈពេលបីថ្ងៃ នៅក្នុងសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន។

សវនាការនេះ បានចាប់ផ្តើមជាសាធារណៈ ដោយប្រធាននៃអង្គបុរេជំនុំជម្រះ ដោយមានការអានរបាយការណ៍ជាសាធារណៈ ដែលបង្ហាញអំពីអង្គហេតុចាំបាច់ និងប្រវត្តិនីតិវិធីនៃសំណុំរឿង ០០៤/២ ក៏ដូចជាសេចក្តីលម្អិតនៃបណ្តឹងឧទ្ធរណ៍ ដែលមានចំពោះមុខអង្គបុរេជំនុំជម្រះ។ របាយការណ៍នេះ ត្រូវបានចេញក្នុងនាមអង្គបុរេជំនុំជម្រះទាំងមូល ហើយត្រូវបានដាក់ក្នុងសំណុំរឿង។ សំណៅសាធារណៈកោសលុបនៃរបាយការណ៍នេះអាចរកបានតាមរយៈគេហទំព័រ https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D359_7_Redacted_KH.PDF និង https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D360_16_Redacted_KH.PDF

ដំណាក់កាលបន្តបន្ទាប់នៃសវនាការ ត្រូវបានធ្វើឡើងជាអសាធារណៈ ដែលសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បានបង្ហាញអំពីទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ សវនាការនេះនឹងបន្តនៅថ្ងៃទី២០ និងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្របទៅតាមដីកាកំណត់កាលបរិច្ឆេទដែលបានចេញនៅថ្ងៃទី០៣ ខែមិថុនាឆ្នាំ២០១៩។

***សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖***

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦
ទូរស័ព្ទលើតុ: +៨៥៥(0)២៣៨៦១៥៦៤
អ៊ីមែល: neth.pheaktra@eccc.gov.kh